00291608

E5/10/4

នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង
នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

**សំណុំរឿងលេខ:** ០០១/១៨-០៧-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

**ដាក់តម្កល់ជូន:** អង្គជំនុំជម្រះសាលាដំបូង

**កាលបរិច្ឆេទដាក់ឯកសារ:** ២៤ មីនា ឆ្នាំ២០០៩

**ភាគីដាក់តម្កល់:** មេធាវីលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច

**ភាសាដើម:** ភាសាខ្មែរ

**ប្រភេទឯកសារ:** សាធារណៈ

---

## ឧឡ្ហីករណ៍មេធាវីការពារក្តីលោក កាំង ហ្កេកអ៊ាវ ហៅ ឌុច អំពីខ្សែភាពយន្តពីរវគ្គដែលដាក់ដោយសហព្រះរាជអាជ្ញា

---

**អ្នកដាក់តម្កល់:**

សហមេធាវី
កាំង ហ្កេកអ៊ាវ
លោក ការ សាវុត្ថ
លោក François ROUX

**តម្កល់ជូន:**

**អង្គជំនុំជម្រះសាលាដំបូង**
ចៅក្រម និល ណុន ប្រធាន
ចៅក្រម Silvia CARTWRIGHT
ចៅក្រម យ៉ា សុខន
ចៅក្រមJean-Marc LAVERGNE
ចៅក្រម ធូ មណី

**ចម្លងជូន:**

**សហព្រះរាជអាជ្ញា**
លោកស្រី ជា លាង
លោក Robert PETIT

**ចម្លងជូន:**

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
មេធាវី គង់ ពិសី
មេធាវី ហុង គឹមសួន
មេធាវី យុង ផានិត
មេធាវី គឹម ម៉េងឃី
មេធាវី ម៉ុច សុវណ្ណារី
Me Silke STUDZINSKY
Me Martine JACQUIN
Me Philippe CANNONE
មេធាវី ទី ស្រីនណា
Me Pierre Olivier SUR
Me Alain WERNER
Me Brianne McGONIGLE
Me Annie DELAHAIE
MeElizabethRABESANDRATANA
Me Karim KHAN

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 24 / 03 / 2009
ម៉ោង (Time/Heure): 16:00
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

ឯកសារបានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
CERTIFIED COPY/COPIE CERTIFIÉE CONFORME
ថ្ងៃ ខែ ឆ្នាំ នៃការបញ្ជាក់ (Certified Date/Date de certification): 25 / 03 / 2009
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: UCH ARUN

# គោរពជូនអង្គជំនុំជម្រះសាលាដំបូង

១. តាមរយៈសេចក្តីសម្រេចចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ២០០៩[1] អង្គជំនុំជម្រះសាលាដំបូងបានជូនដំណឹងដល់ជនជាប់ចោទ លោក **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** តាមរយៈមេធាវីការពារក្តីរបស់គាត់ "ឲ្យបង្ហាញនូវទឡ្ហីករណ៍ជាលាយលក្ខណ៍អក្សរអំពីខ្សែភាពយន្តពីរវគ្គដែលដាក់ដោយសហព្រះរាជអាជ្ញា" យ៉ាងយូរបំផុតត្រឹមថ្ងៃទី ២៤ ខែ មីនា ឆ្នាំ ២០០៩។

២. មេធាវីការពារក្តីសូមដាក់ជូនអង្គជំនុំជម្រះសាលាដំបូង នូវទឡ្ហីករណ៍ដូចខាងក្រោម ដើម្បីឆ្លើយតបនឹងពាក្យសុំរបស់សហព្រះរាជអាជ្ញា ស្តីពីខ្សែភាពយន្តឯកសារពីរវគ្គ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩[2]។

៣. មជ្ឈមណ្ឌលឯកសារកម្ពុជា(DC-Cam) បានផ្តល់ខ្សែភាពយន្តពីរវគ្គនេះជូន សហព្រះរាជអាជ្ញា កាលពីថ្ងៃទី០៨ ខែមករា ឆ្នាំ២០០៩។ ក្រោយពីបានពិនិត្យមើលដោយយកចិត្តទុកដាក់ សហព្រះរាជអាជ្ញាបានកំណត់ថា ខ្សែភាពយន្តនេះ ជាប់ទាក់ទងទៅនឹងសំណុំរឿងលេខ ០០១ ព្រោះមានរូបភាពនានាអំពីមន្ទីរស-២១ ដែលត្រូវបានគេថតនៅពេលភ្លាមៗ បន្ទាប់ពីការរុករកឃើញមន្ទីរនេះដោយកងកម្លាំងកងទ័ពវៀតណាម។

៤. ប៉ុន្តែ ក្រោយពីបានពិនិត្យមើលខ្សែភាពយន្តនេះយ៉ាងយកចិត្តទុកដាក់ សហមេធាវីការពារក្តីយល់ឃើញថា ខ្សែភាពយន្តនេះមិនអាចទទួលយកបានទេ ហើយមិនសមហេតុសមផល ដោយមូលហេតុដូចតទៅ ៖

៥. **ទីមួយ** ខ្សែភាពយន្តនេះជាខ្សែភាពយន្តនយោបាយដែលបំផ្លែងព័ត៌មានដ៏កំពោល។ ជាក់ស្តែង តាមបទយកការណ៍របស់វិទ្យុបារាំងអន្តរជាតិ(RFI)ផ្សាយជាខេមរៈភាសា ដែលបានផ្សាយកាល

---

[1] សូមអាន *សេចក្តីសម្រេចអំពីភាពអាចទទួលយកបាននៃភស្តុតាងថ្មី និង សេចក្តីណែនាំដល់ភាគីទាំងអស់* របស់អង្គជំនុំជម្រះសាលាដំបូង ចុះថ្ងៃទី ១០ ខែ មីនា ឆ្នាំ ២០០៩ (E5/10/2)។

[2] សូមអាន *ពាក្យសុំរបស់សហព្រះរាជអាជ្ញា ដើម្បីដាក់បន្ថែមនូវភស្តុតាងថ្មីៗ* ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០០៩ (E5/10)។

ពីថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩ (វេលាម៉ោង ១៣ និង ៤២ នាទី ម៉ោងសាកល) បានដកស្រង់យកសំដីរបស់ លោក Fançois Ponchaud ថា "ខ្សែភាពយន្តដែលវៀតណាមថត ជាខ្សែភាពយន្តបែបនយោបាយ"[3] ។

៦. **ទីពីរ** ខ្លោងទ្វារធំចូល ស-២១ ស្ថិតនៅទិសខាងកើត តាមផ្លូវលេខ ១១៣ តែនៅក្នុងខ្សែភាពយន្តនេះ ខ្លោងទ្វារធំស្ថិតនៅទិសខាងលិច តាមផ្លូវលេខ ១៣១ ទៅវិញ ។

៧. ម្យ៉ាងទៀត ខ្សែភាពយន្តនេះបង្ហាញនូវស្លាកមួយដែលមានសរសេរថា "សាលាបឋមសិក្សាទួលស្លែង" (ស្ថិតនៅទិសខាងលិច)។ ប៉ុន្តែ តាមការពិត មន្ទីរ ស-២១ (ដែលមានផ្លូវចូលនៅទិសខាងកើត) គ្មានស្លាកណាមួយនៅលើខ្លោងទ្វារចូលទេ ។ ដូច្នេះគឺពិតជាមានការក្លែងបន្លំពិតមែន ។

៨. **ទីបី** នៅថ្ងៃទី២ ឬ ទី៣ ខែ មករា ឆ្នាំ ១៩៧៩ នួន ជា បានបញ្ជាឱ្យមន្ទីរស-២១ បញ្ជូនជនជាប់ឃុំឃាំងទាំងអស់ទៅជើងឯក។

៩. **ឌុច** បានស្នើសុំទៅ នួន ជា ដើម្បីទុកជនជាប់ឃុំឃាំងមកពីអង្គភាព **យ.៨** សម្រាប់សួរចម្លើយតទៅទៀត គឺយុទ្ធជន៤នាក់ដែលមកពីអង្គភាពនេះ។ អ្នកសួរចម្លើយបានសម្លាប់យុទ្ធជនទាំងបួននាក់នេះ មុននឹងរត់ចេញពីមន្ទីរ ស-២១ នៅថ្ងៃទី៧ ខែមករា ឆ្នាំ១៩៧៩។ ព្រឹត្តការណ៍នេះបញ្ជាក់ថា គ្មានសាកសពឯណាផ្សេងទៀតក្រៅពីសាកសពយុទ្ធជនទាំងបួននាក់ដែលពួកស-២១ រត់ចោលមិនបានកប់នោះទេ។

១០. **ឌុច** បានឱ្យដឹងថា នៅថ្ងៃទី៧ ខែមិថុនា ឆ្នាំ២០០៧ ទូរទស្សន៍ជប៉ុន ឬថ្ងៃទី១៥ ខែ មិថុនា ឆ្នាំ២០០៧ ទូរទស្សន៍អ៊ីតាលី បានបង្ហាញឱ្យគាត់មើលនូវរូបថតយុទ្ធជនម្នាក់ដេកស្លាប់លើគ្រែ។ សាកសពនេះមានស្លៀកពាក់ខោអាវ សាច់មិនទាន់ហើមនិងរលួយនៅឡើយទេ។ **ឌុច** ទទួលស្គាល់ថា សាកសពនេះជាមនុស្សម្នាក់ក្នុងចំណោមបួននាក់ដែលមកពីអង្គភាព **យ.៨** ដែលត្រូវបានសម្លាប់នៅថ្ងៃចុងក្រោយ នៅមន្ទីរ ស-២១ ហើយត្រូវបានទុកចោលនៅលើគ្រែ។

[3] សូមមើល ឧបសម្ព័ន្ធ ក ៖ បទសម្ភាស់របស់ Francois Ponchaud ដោយវិទ្យុបារាំងអន្តរជាតិ (RFI) ផ្សាយថ្ងៃទី០៤ ខែកុម្ភៈ ឆ្នាំ២០០៩ (ជាទម្រង់ CD)។

១១. ក៏ប៉ុន្តែ ចំនួនសាកសពដែលបានបង្ហាញក្នុងខ្សែភាពយន្តពីរវគ្គនេះមានចំនួនលើសពីបួននាក់ ហើយមិនមែនជាសាកសពយុទ្ធជនមកពីអង្គភាព **យ.៨** ទេ។ ដូច្នេះ បើតាម **ឌុច** នេះគឺជាហេតុការណ៍មួយដែលគេប្រឌិតឡើង។

១២. **ទីបួន** នៅថ្ងៃទី២ ឬ ទី៣ ខែមករា ឆ្នាំ១៩៧៩ ជនរងគ្រោះទាំងប៉ុន្មានដែលនៅសេសសល់នៅ ស-២១ ត្រូវបានសម្លាប់ចោលទាំងអស់។ ហើយក៏គ្មានមនុស្សណាម្នាក់ត្រូវបានចាប់បញ្ជូនចូល ស-២១ ដែរ នៅក្រោយថ្ងៃទី៣ ខែមករា ឆ្នាំ១៩៧៩ ។ ដូច្នេះ អ្វីៗទាំងអស់នាំឱ្យជឿជាក់បានថា គ្មានកុមារណាម្នាក់អាចនៅមានជីវិតទៀតឡើយ នៅពេលដែលកងកម្លាំងកងទ័ពវៀតណាមមកដល់។

១៣. ម្យ៉ាងទៀត ខ្សែភាពយន្តបានបង្ហាញថា អគារមួយត្រូវបានតុបតែងឱ្យទៅជាកន្លែងដែលគេចងអង្រឹងសម្រាប់កុមារ។ អគារនេះគឺជារោងជាងរបស់មន្ទីរស-២១ ដែលតាមធម្មតា គួរតែនៅមានសេសសល់របស់របរស្អិតនៅរាយប៉ាយ បន្ទាប់ពីការចាកចេញដ៏ប្រញាប់ប្រញាល់របស់បុគ្គលិកមន្ទីរស-២១។ ការណ៍ដែលអគារមានលក្ខណៈស្រឡះបែបនេះ គឺពិតជាគេរៀបចំឡើងសំរាប់ការថតភាពយន្ត ពីព្រោះរោងជាងនេះមានដំណើរការរាល់ថ្ងៃ ហើយមិនដែលមានអង្រឹងណាមួយត្រូវបានគេចងសម្រាប់កុមារឬទារកនោះទេ។ មន្ទីរស-២១ គ្មាននយោបាយដែលផ្ដល់ដល់ទារកឬកុមារ នូវអង្រឹងនីឡុងឱ្យប្រើនោះទេ។

១៤. នៅទីបញ្ចប់ ស្ថានភាពឃុំឃាំងរបស់ជនរងគ្រោះ ទាំងក្មេង ទាំងចាស់ នៅមន្ទីរស-២១ មានសភាពលំបាកណាស់ ជាអាទិ៍ដូចជាត្រូវគេបង្អត់អាហារជាដើម។ ក៏ប៉ុន្តែ ទារកនិងកុមារនៅក្នុងខ្សែភាពយន្តនេះ ហាក់ដូចជាមានសុខភាពល្អ ។ ដូច្នេះហើយ យើងអាចមានមន្ទិលថា ទារកនិងកុមារទាំងនោះពិតជាមិនត្រូវបានឃុំឃាំងនៅ ស-២១ ទេ។ ម្យ៉ាងទៀត យើងក៏អាចបារម្ភថា ប្រសិនបើកុមារទាំងនោះត្រូវបានគេទុកចោលម្នាក់ឯងនៅ ស-២១ មែននោះ វាមិនអាចគេចផុតពីសេចក្ដីស្លាប់ លើសពីរបីថ្ងៃបានឡើយ។

១៥. នៅចុងបញ្ចប់ នៅពេលដែលលោក **កាំង ហ្គេកអ៊ាវ** ហៅ **ឌុច** បានចាកចេញពីមន្ទីរស-២១ នៅថ្ងៃទី ៧ ខែមករា ឆ្នាំ១៩៧៩ វេលាម៉ោង១៤នោះ មាននៅសល់ជនរងគ្រោះ ដែលជាអតីតអ្នកទោសរបស់មន្ទីរ ស-២១ ចំនួន៩នាក់ ដែលនៅរស់រានមានជីវិតរហូតដល់ពេលបច្ចុប្បន្ន ដូចជាលោក **វ៉ាន់ ណាត** លោក **ប៊ូ ម៉េង** និងលោក **ជុំ ម៉ី**។ ខ្សែភាពយន្តនេះគួរតែថតអ្នកទាំង៩ នាក់នេះ ដើម្បីរៀបរាប់រឿងរ៉ាវពិតនៅ ស-២១។

១៦. យោងតាមការអធិប្បាយខាងលើនេះ សហមេធាវីការពារក្តីយល់ឃើញថា ខ្សែភាពយន្តពីរវគ្គនេះ គឺជាខ្សែភាពយន្តដែលត្រូវបានគេប្រឌិតឡើង ដែលមានលក្ខណៈនយោបាយ។

១៧. ជាសេចក្តីសន្និដ្ឋាន សហមេធាវីការពារក្តីសូមស្នើទៅអង្គជំនុំជម្រះសាលាដំបូង ឱ្យផាត់ភស្តុតាងថ្មីនេះ ចេញពីសំណុំរឿងលេខ ០០១។

## សុំរក្សាសិទ្ធិកែប្រែគ្រប់យ៉ាង

| | | |
|---|---|---|
| មេធាវីម្នាក់សំរាប់មេធាវីទាំងពីររូប<br><br>លោក **ការ សាវុត្ថ** | ភ្នំពេញ | [signature] |
| ឈ្មោះ | ទីកន្លែង | ហត្ថលេខា |